ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៥៩/១១-ផ្លេកថាម (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**
ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ប្រេក្ត ផ្លេកថាម (ខេមបូឌា) អ៊ីភែរីល លីមីធីត**
អាសយដ្ឋាន ៖ ភូមិផ្សារកំបូល សង្កាត់កំបូល ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៨៧៧ ៩៦៧ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការលើកទី១ និងទី២ ៖

| | |
|---|---|
| ១- លោក តេង សម្បត្តិ | ប្រធានរដ្ឋបាល |
| ២- លោក ប៊ី លី | ជំនួយការ |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ
- សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន ផ្លេកថាម

អាសយដ្ឋាន ៖ ភូមិផ្សារកំបូល សង្កាត់កំបូល ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៧ ៤៣០ ៣១២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការលើកទី១ ៖

| | |
|---|---|
| ១- លោក ហ៊ីង ប៊ុនធឿន | អនុប្រធានសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |
| ២- លោក មុំ ផុក | ប្រធានសហជីពស្មារតីកម្មករខ្មែរប្រចាំរោងចក្រ |
| ៣- កញ្ញា ជឹន សុខលី | អនុប្រធានសហជីព |
| ៤- កញ្ញា ស្វាយ តឿ | លេខាធិការិនីសហជីព |
| ៥- កញ្ញា មុំ ចាន់ណា | កម្មការិនី |
| ៦- កញ្ញា សាំង ស្រីយឿន | កម្មការិនី |

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការលើកទី២ ៖

| | |
|---|---|
| ១- លោក ហ៊ីង ប៊ុនធឿន | អនុប្រធានសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |
| ២- លោក មុំ ផុក | ប្រធានសហជីពស្មារតីកម្មករខ្មែរប្រចាំរោងចក្រ |
| ៣- លោក ឈាង ភិន | មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |
| ៤- កញ្ញា ស្វាយ តឿ | លេខាធិការិនីសហជីព |
| ៥- កញ្ញា ឈឹម អូន | កម្មការិនី |
| ៦- កញ្ញា សាំង ស្រីយឿន | កម្មការិនី |
| ៧- លោក ឆុំ សេងគាង | មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនទទួលយកលោក មុំ ផុក ដែលជាថ្នាក់ដឹកនាំសហជីពស្មារតីកម្មករខ្មែរចូលធ្វើការជាធម្មតាវិញ ។

២- សូមឱ្យក្រុមហ៊ុនរៀបចំទឹកហូបឱ្យបានគ្រប់គ្រាន់ និងមានអនាម័យ ។

៣- សូមឱ្យក្រុមហ៊ុនសងប្រាក់ថ្លៃពិនិត្យសុខភាពឱ្យកម្មករនិយោជិតតាមការជាក់ស្តែង ។

៤- នៅពេលកម្មករនិយោជិតដេរបាក់ម្ជុលម្តងម្កាល ហើយទៅសុំដូរត្រូវផ្តល់ភាពងាយស្រួល ។

៥- នៅពេលកម្មករមានគ្រោះថ្នាក់ការងារសូមឱ្យក្រុមហ៊ុនទទួលខុសត្រូវលើថ្លៃព្យាបាលនិងអត្ថប្រយោជន៍ផ្សេងៗ ។

៦- សូមឱ្យក្រុមហ៊ុនសំអាតបន្ទប់ទឹកឱ្យបានស្អាត និងមានសាប៊ូ កន្លែងប្រើប្រាស់ផង ។

៧- សូមឱ្យក្រុមហ៊ុនរៀបចំដាក់ថ្នាំពេទ្យ ឱ្យបានគ្រប់គ្រាន់ជូនកម្មករ ។

៨- នៅពេលកម្មករឈឺ ហើយមានលិខិតបញ្ជាក់ត្រឹមត្រូវពីពេទ្យ ដែលទទួលស្គាល់ដោយរដ្ឋ សូមឱ្យក្រុមហ៊ុនរក្សាអត្ថប្រយោជន៍ផ្សេងៗនៅដដែល ។

THE ARBITRATION COUNCIL

៩- នៅពេលកម្មករមានកំហុសស្រាល សូមឱ្យក្រុមហ៊ុនហៅគាត់មកធ្វើការណែនាំជាមុនសិន កុំបញ្ឈប់គាត់ពីការងារ ។

១០- សូមឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូនជូនកម្មការិនី ។

១១- សូមឱ្យក្រុមហ៊ុនបញ្ឈប់សកម្មភាពផ្តាច់កិច្ចសន្យាការងាររបស់កម្មករ ដែលមានកំហុស ។

១២- សូមឱ្យក្រុមហ៊ុនណែនាំប្រធានក្រុមគ្រប់ក្រុមគ្រប់ផ្នែក ដែលតែងតែប្រើពាក្យសម្តីមិនសមរម្យមកលើកម្មករ ។

១៣- ចំពោះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលកម្មករនិយោជិតទាំងអស់ធ្វើកូដកម្ម រហូតដល់ថ្ងៃចូលធ្វើការវិញ សូមឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់ធ្វើការទៀងទាត់នៅដដែល ។

១៤- នៅពេលកម្មកសុំច្បាប់ឈប់សម្រាកពេលមានធុរៈផ្សេងៗ សូមឱ្យក្រុមហ៊ុនអនុញ្ញាតច្បាប់ឱ្យមានភាពងាយស្រួលជូនពួកគាត់ ។

១៥- សូមឱ្យក្រុមហ៊ុនដកបុគ្គលិកឈ្មោះ រ័ត្ន តួនាទីជាជំនួយការរដ្ឋបាល ឈ្មោះ ភារម្យ តួនាទីជាជាងម៉ាស៊ីន ដែលអ្នកទាំងពីរនោះតែងតែប្រមាថមើលងាយ និងប្រើពាក្យសំដីមិនសមរម្យមកលើកម្មករ ។

១៦- សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់លើកទឹកចិត្តមួយថ្ងៃមួយដុល្លាដល់កម្មករម្នាក់ៗនៅដដែល ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៣៣០ កប/អក/វក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងប្រជុំមុនសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទប្រជុំមុនសវនាការ ៖

- លើកទី ១ ៖ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ (វេលាម៉ោង ១៣ និង ៣០ នាទី រសៀល ) ។

- លើកទី ២ ៖ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១ (វេលាម៉ោង ១៦ និង ៣០ នាទី រសៀល )។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ កម្មករនិយោជិតប្រមាណជាង ១៥០ នាក់ ដឹកនាំដោយសហព័ន្ធសហជីពស្មារតីកម្មករខ្មែរបានធ្វើកូដកម្ម ដើម្បីទាមទារឱ្យក្រុមហ៊ុនកែលំអរនូវលក្ខខណ្ឌការងារមួយចំនួន១៦ចំណុច។ បន្ទាប់ពីបានព័ត៌មានកូដកម្មនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការផ្សះផ្សាវិវាទការងារនេះដល់ទីតាំងរោងចក្រ ប៉ុន្តែភាគីទាំងពីរមិនឯកភាពទេ ដោយភាគីក្រុមហ៊ុនបញ្ជាក់ថា កម្មករនិយោជិតត្រូវចូលធ្វើការជាធម្មតាសិន ទើបក្រុមហ៊ុនធ្វើការចរចារ ហើយការចរចានេះទៀតធ្វើឡើងជាមួយតំណាងកម្មករនិយោជិតប្រចាំក្រុមហ៊ុនផ្ទាល់ ព្រោះរោងចក្រនេះមិនទាន់មានសហជីពនៅឡើយ។ ចំណែកឯភាគីកម្មករនិយោជិតចង់បានការដោះស្រាយដោយមានការចូលរួមពីសហព័ន្ធសហជីពរួចរាល់សិន ទើបចូលធ្វើការងារវិញ។

ហេតុនេះ នៅរសៀលថ្ងៃដដែល នាយកដ្ឋានវិវាទការងារបានបន្តធ្វើការផ្សះផ្សាភាគីទាំងពីរ ប៉ុន្តែនៅតែមិនទទួលបានលទ្ធផលសះជានឹងគ្នាលើចំណុចទាំង១៦ដដែល។ ចំណុចមិនសះជាចំនួន១៦ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ផ្លេកថាម (ខេមបូឌា) លេខ ១៣៣០ កប/អក/វក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ដោយសារតែការធ្វើកូដកម្មនៅតែបន្ត និងយោងតាមសំណើររបស់ក្រុមហ៊ុន ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ សុំជួយអន្តរាគមន៍ ដើម្បីឱ្យកម្មករនិយោជិតចូលធ្វើការវិញនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០១៥/១១ កបអ. ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ ឱ្យផ្អាកជាបន្ទាន់ការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ផ្លេកថាម (ខេមបូឌា) រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកម្មករនិយោជិតដែលធ្វើកូដកម្មទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីរសៀលថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ តទៅ តាមវេនរបស់ខ្លួន។

ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ លេខាធិការដ្ឋានក្រុមប្រឹក្សាក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមទូរស័ព្ទពីភាគីកម្មករនិយោជិតថា ក្រុមហ៊ុនមិនអនុវត្តតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ពោលគឺក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករនិយោជិត ដែលបានចូលធ្វើកូដកម្មត្រឡប់ចូលធ្វើការទាំងអស់ លើកលែងតែលោក មុំ ថុក ប្រធានសហជីពស្មារតីកម្មករខ្មែរ ដោយរង់ចាំការដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលសិន។ ដោយឡែកភាគីកម្មករនិយោជិតបានបញ្ជាក់ជំហរថា អាចចូលធ្វើការបាន លុះត្រាតែក្រុមហ៊ុនទទួលយកលោក មុំ ថុក ចូលធ្វើការដែរ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះអញ្ជើញភាគីក្រុមហ៊ុន និងកម្មករនិយោជិតមកចូលរួមកិច្ចប្រជុំ ដើម្បីសាកសួរព័ត៌មានស្តីពីកូដកម្ម នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ១៣ និង ៣០ នាទី រសៀល នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ភាគីទាំងពីរមានវត្តមានតាមការអញ្ជើញ។ ក្នុងកិច្ចប្រជុំមុនសវនាការនេះ ជាបឋម ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពន្យល់ប្រាប់ភាគីទាំងពីរអំពីនីតិវិធីសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល និងស្នើឱ្យភាគីទាំងពីររក្សាភាពស្ងប់ស្ងាត់ចៀសវាងការធ្វើវិវាទឱ្យកាន់តែធ្ងន់ធ្ងរ។ មាន

ន័យថា កម្មករនិយោជិតត្រូវបញ្ឈប់ការធ្វើកូដកម្ម ចំណែកភាគីនិយោជកត្រូវបើកទ្វារឱ្យកម្មករនិយោជិតចូលធ្វើការធម្មតាវិញ។ ជាដំបូង ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតនឹងមិនចូលធ្វើការវិញ ប្រសិនបើនិយោជកមិនអនុញ្ញាតឱ្យលោក មុំ ផុក ចូលធ្វើការវិញ ពីព្រោះដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញមិនបានកំណត់ថា ឱ្យគាត់នៅខាងក្រៅរោងចក្រទេ។ ពោលគឺនិយោជកបានបំពាននឹងដីកាសម្រេចរក្សាការពារ និងសេចក្តីបញ្ជារបស់ក្រុមអាជ្ញាកណ្តាល។ ចំណែកភាគីនិយោជកបញ្ជាក់ថា គាត់មិនអនុញ្ញាតឱ្យកម្មករនិយោជិតចូលធ្វើការទេ ដោយចាត់ទុកថា កម្មករនិយោជិតបោះបង់ចោលការងារ ពីព្រោះពួកគាត់មិនចូលធ្វើការក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញចេញដីកាសម្រេចរក្សាការពារ។ ជំហរចុងក្រោយនៅក្នុងកិច្ចប្រជុំនេះ គឺថា ភាគីកម្មករនិយោជិតយល់ព្រមចូលធ្វើការធម្មតាសិន លើកលែងតែលោក មុំ ផុក ចេញ។ ទោះជាយ៉ាងណា ភាគីនិយោជកសូមធ្វើការពិចារណាលើបញ្ហានេះបន្ថែមទៀត ដោយមិនទាន់អាចសម្រេចទទួលយកកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញទេ ទោះបីជាត្រូវលើកលែងលោក មុំ ផុក ចេញក៏ដោយ។

នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមទូរស័ព្ទពីភាគីនិយោជក និងកម្មករនិយោជិតថា និយោជកបានបញ្ឈប់កម្មករនិយោជិតទាំងអស់ ដែលបានធ្វើកូដកម្មនេះ ដោយអនុវត្តតាមដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានកោះអញ្ជើញភាគីនិយោជក និងកម្មករនិយោជិត មកចូលរួមកិច្ចប្រជុំដើម្បីសាកសួរព័ត៌មានបន្ថែមទៀត ជាលើកទី២ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ១៦ និង ៣០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានតាមការអញ្ជើញ។ ក្នុងកិច្ចប្រជុំលើកទី២នេះ ភាគីកម្មករនិយោជិតបានបញ្ជាក់ជំហរដដែលថា ពួកគាត់សុខចិត្តចូលធ្វើការវិញ លើកលែងលោក មុំ ផុក ដើម្បីទុកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលបន្តនីតិវិធីរបស់ខ្លួន។ ចំណែកភាគីនិយោជកវិញមិនឯកភាពទេ ហើយនៅតែប្រកាន់ជំហររបស់ខ្លួន ដោយអនុវត្តតាមដីកាសម្រេចរក្សាការពារ ពីព្រោះកម្មករនិយោជិតមិនព្រមចូលធ្វើការក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីពេលចេញដីកាសម្រេចរក្សាការពារ។ នៅមុនបញ្ចប់កិច្ចប្រជុំ ភាគីកម្មករនិយោជិតស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើតាមនីតិវិធីច្បាប់ចុះ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេច ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ផ្លេកថាម លេខ ១៣៣០ កប/អក/វក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ផ្លេកថាម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមកិច្ចប្រជុំមុនសវនាការលេខ ៨៧២ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមកិច្ចប្រជុំមុនសវនាការលេខ ៨៧៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ ។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ នៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការសវនាការបាន។

**ហេតុផលនៃសេចក្តីសម្រេចៈ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ២០ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា " *ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម* " ។

យោងតាមប្រការ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជា*កូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទ កាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្តាល*។

នៅក្នុងសេចក្តីបញ្ជាមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករកំពុងធ្វើកូដកម្ម។

ឧទាហរណ៍ នៅក្នុងសំណុំរឿងសេចក្តីបង្គាប់លេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤នៃសេចក្តីជូនដំណឹងនេះ ចែងថា ៖

" *ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម* "។

ដូចគ្នាដែរ នៅក្នុងរឿងក្តី ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ហ្វ្រែន ឌ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និង សូភីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី

២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

*"ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ"* ។

*"ចំណុចទី១១- ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ"* ។

នៅក្នុងសំណុំរឿង ៧៧/០៦-ហ្វ្រង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿងលេខ ២៨/០៦-ជី ឌី អឹម ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់បិទសំណុំរឿងនោះចោល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ។

នៅក្នុងសំណុំរឿង លេខ ២២/០៧- ផាកវីយូ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់បិទសំណុំរឿងដែរ ពីព្រោះ ក្រោយពីការចេញសេចក្តីបញ្ជាឱ្យកម្មករនិយោជិតផ្អាកកូដកម្មហើយ មានកម្មករនិយោជិតមួយចំនួននៅបន្តធ្វើកូដកម្ម ហើយភាគីនិយោជកវិញបានធ្វើឡុកអៅ ដោយបានបិទទ្វាររោងចក្រមិនឱ្យកម្មករចូលធ្វើការ ។

ចំណែកឯនៅក្នុងសំណុំរឿងលេខ ៤៩/១០-វីង យីង វិញ និយោជកបានសម្រេចបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងអស់នៅក្នុងរោងចក្រ បន្ទាប់ពីក្រុមអាជ្ញាកណ្តាលចេញសេចក្តីបញ្ជាឱ្យភាគីកម្មករនិយោជិតផ្អាកកូដកម្ម នៅក្នុងដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែល ការបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងអស់នៅក្នុងរោងចក្រនេះចាត់ទុកថាជាការចាត់វិធានការដទៃទៀតរបស់និយោជក ដែលធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរនៅក្នុងដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ដោយផ្អែកលើហេតុផលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល ដោយយោងតាមប្រការ ២០ ខាងលើ ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកបានចាត់វិធានការក្នុងការអនុវត្តតាមដីកាសម្រេចរក្សាការពារ ដែលចាត់ទុកថា ជាវិធានការដទៃទៀត ដែលធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរនៅក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ដូចជាការមិនអនុញ្ញាតឱ្យលោក មុំ ផុក ដែលជាប្រធានសហជីពស្មារតីកម្មករខ្មែរចូលធ្វើការសិនតាមស្មារតីនៃដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ និងការមិនគោរពសេចក្តីបញ្ជារបស់ក្រុមអាជ្ញាកណ្តាលជាដើម ។ ការចាត់វិធានការបែបនេះ បានធ្វើឱ្យកម្មករនិយោជិតនៅតែបន្តការតវ៉ាទាមទារឱ្យនិយោជកអនុញ្ញាតឱ្យលោក មុំ ផុក ដែលជាប្រធានសហជីពស្មារតីកម្មករខ្មែរចូលធ្វើការសិន ទើបកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញ ។ ជាលទ្ធផលកម្មករនិយោជិតមិនព្រមចូលធ្វើការក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញចេញដីកាសម្រេចរក្សាការពារនោះឡើយ ។ ការចាត់វិធានការអនុវត្តដីការក្សាការពារសាលាដំបូងរាជធានីភ្នំពេញដោយលើកលែងលោក មុំ ផុក ដែលជាប្រធានសហជីពស្មារតីកម្មករខ្មែរនេះធ្វើឱ្យវិវាទរវាងកម្មករនិយោជិត និងនិយោជកកាន់តែធ្ងន់ធ្ងរទៅនៅក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ។

នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាលទាំងពីរលើក នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ និងនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១ ភាគីកម្មករនិយោជិតបានយល់ព្រមចូលធ្វើការធម្មតាសិន លើកលែងតែ លោក មុំ ថុក ដែលជាប្រធានសហជីពស្មារតីកម្មករខ្មែរចេញ ដើម្បីទុកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលបន្តនីតិវិធីរបស់ខ្លួន។ ប៉ុន្តែ ចំណែកភាគីនិយោជកវិញ មិនឯកភាពទេ និងមិនគោរពតាមសេចក្ដីបញ្ជារបស់ក្រុមអាជ្ញាកណ្ដាលឡើយ ដោយនៅតែប្រកាន់ជំហររបស់ខ្លួនក្នុងការអនុវត្តតាមដីកាសម្រេចរក្សាការពារ ដោយបានសម្រេចបញ្ឈប់កម្មករនិយោជិតទាំងអស់ ដែលបានចូលរួមកូដកម្មពីដំបូង ពីព្រោះនិយោជកយល់ថា ពួកគាត់មិនចូលធ្វើការក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញចេញដីកាសម្រេចរក្សាការពារ។

ផ្អែកលើការបកស្រាយខាងលើក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីនិយោជកបានចាត់វិធានការរបស់ខ្លួនដែលធ្វើឱ្យស្ថានភាពវិវាទនេះកាន់តែធ្ងន់ធ្ងរ។ លើសពីនេះ នៅក្នុងកិច្ចប្រជុំលើកទី២ ភាគីកម្មករនិយោជិតនិងនិយោជកបានលើកឡើងថា កម្មករនិយោជិតដែលធ្វើការទាមទារនៅក្នុងសំណុំរឿង ១៥៩/១១-ផ្លេកថាម នេះត្រូវបាននិយោជកបញ្ឈប់ពីការងារអស់ទៅហើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ប្រសិនបើក្រុមប្រឹក្សាអាជ្ញាកណ្ដាលបន្តសវនាការលើសំណុំរឿងនេះ ភាគីដើមបណ្ដឹង ឬអ្នកដែលនឹងទទួលប្រយោជន៍ពីសេចក្ដីសម្រេចនៃសំណុំរឿងនេះ ក៏មិនមានទៀតដែរ។ ជាចុងក្រោយ ភាគីកម្មករនិយោជិតបានសំណូមពរឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចតាមនីតិវិធីច្បាប់ចុះ។

ដូច្នេះ ដោយផ្អែកតាមប្រការ ២០ នៃប្រកាស ០៩៩ និងដើម្បីឱ្យស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងមុនៗពាក់ព័ន្ធនឹងប្រការ២០នេះ (ករណីកូដកម្ម ឡុកអៅ និងការចាត់វិធានការវិវាទដទៃទៀត ដែលធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ) ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះទេ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចដូចតទៅ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ១៥៩/១១-ផ្លេកថាម នេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក៖

ឈ្មោះ៖ **អ៊ុំ សុន្ធី**

ហត្ថលេខា: ------------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖

ឈ្មោះ៖ **លឹម សុវណ្ណា**

ហត្ថលេខា: ------------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា: ----------------------------------------